ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ: ធ៥-០១៥-៣៧៧៩ ធ.ស.ហ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបន្ថយតម្លៃចារឹករបស់មូលបត្រអាចជួញដូរបាន និងការឈប់ផ្តល់សេវាទទួលប្រាក់បញ្ញើមានកាលកំណត់

ក្នុងគោលបំណងជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ និងបង្កលក្ខណៈងាយស្រួលដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្នុងការគ្រប់គ្រងសន្ទនីយភាពប្រកបដោយប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាមានកិត្តិយស សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជ្រាបថា តម្លៃចារឹក (Face Value) អប្បបរមារបស់មូលបត្រអាចជួញដូរបាន (NCD) ជាប្រាក់រៀលនឹងត្រូវបន្ថយពី ២ ប៊ីលានរៀល មក ២០០ លានរៀល និងជាប្រាក់ដុល្លារអាមេរិកពី ៥០០ ពាន់ដុល្លារ មក ៥០ ពាន់ដុល្លារ ។

ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជានឹងឈប់ផ្តល់សេវាទទួលប្រាក់បញ្ញើមានកាលកំណត់ចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៥ នេះតទៅ ។

សេចក្តីជូនដំណឹងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៥ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ខែតុលាឆ្នាំ២០១៥

**ត.ប ទេសាភិបាល**

**អគ្គនាយកបច្ចេកទេស**

**ជា សិរី**

**កន្លែងទទួល**

- គ្រប់អគ្គនាយកដ្ឋាន "ដើម្បីជូនជ្រាប"
- នាយកដ្ឋានពាក់ព័ន្ធ
- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- គ្រប់សាខាធនាគារជាតិនៃកម្ពុជា

"ដើម្បីជ្រាបនិងសហការអនុវត្ត"

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧